សមាគមខ្មែរ នៃ រ៉ូដអៃឡិន្ត
Cambodian Society of Rhode Island, Inc.
177-179 Hanover Street, Provident RI 02907, Tel: 401 437 6264, Fax: 401 437 6265 Email: csri-sourn@hotmail.com

សហរដ្ឋអាមេរិក ខែមករា ថ្ងៃទី៤ ឆ្នាំ២០០៧

ជូន លោក ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃកម្ពុជា

លោក ជាទីរាប់អាន

ក្នុងនាមខ្ញុំ ជាប្រជាជាតិខ្មែរមួយរូបដែលកំពុងរស់នៅឆ្ងាយពីមាតុភូមិ ក៏ដូចជាប្រជាជាតិខ្មែរ ដ៏ទៃទៀតដែរគឺតែងតែប្រាថ្នាចង់ឃើញ ប្រទេសកំណើតរបស់ខ្លួនគឺ កម្ពុជា ក្លាយជាប្រទេសដែលមានការ គោរពលទ្ធិប្រជាធិបតេយ្យ គោរពសិទ្ធមនុស្ស និងអនុវត្តនូវនីតិរដ្ឋពិតប្រាកដ។ ពោលគឺមិនមែនចង់ ឃើញនូវការដឹកនាំមួយ ដែលបុគ្គលម្នាក់ និងបក្សមួយក្រុមប្រើអំណាចគ្របដណ្តប់ច្បាមក្តាប់យកកម្ពុជាធ្វើជាកម្មសិទ្ធផ្តាច់មុខ ហើយទុកប្រជាពលរដ្ឋដូចជាទាសករនយោបាយនោះទេ ដើម្បីបំពេញមហេច្ឆតានយោបាយដ៏ពិសពុលរបស់ខ្លួននោះទេ។

ក្នុងលទ្ធិប្រជាធិបតេយ្យ បើហ៊ានទទួលយកការបោះឆ្នោតធ្វើជាការផ្សងសំណាង គឺត្រូវតែទទួលយកវេទិការឃោសនាដោយសេរី និងមិនត្រូវក៏រិតការនិយាយស្តីទៅលើបេក្ខជនអ្នកនយោបាយនោះទេ។ សេចក្តីថ្លែងការថ្មីៗរបស់លោក ពីអតិតតំបន់រដ្ឋបាលខ្មែរក្រហម (អន្លងវែង) ដែលហាមឃាត់មិនអោយអ្នកនយោបាយយករឿងអាសោច ឬរឿងអាក្រក់ ឬក៏រឿងអាស្រូវ ក្នុងការដឹកនាំរបស់អ្នកនយោបាយផ្សេងទៀត មកនិយាយក្នុងពេលឃោសនា វាគឺជាការក៏រិតនូវសេរីភាពរបស់អ្នកនយោបាយ និងជាចេតនាបាំងបិទនូវទង្វើរបស់អ្នកនយោបាយទុច្ចរិត និងបុគ្គលអាក្រក់ដែលភាគច្រើនមានសមាសភាពក្នុង គណៈបក្សប្រជាជនកម្ពុជា របស់លោក និងគណៈបក្សហ៊្វុនស៊ិនប៉ិច ជាដៃគូរនៃរដ្ឋាភិបាលរបស់លោក។ ជាការពិតការ ការពារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈចំពោះអ្នកនយោបាយ និងប្រជាពលរដ្ឋគ្រប់រូប វាពិតជាពិតជាកាតព្វកិច្ចនៃរដ្ឋាភិបាលរបស់លោក តែមិនមែនមានន័យថា លោកត្រូវតែយកលែស ឬចង់ទាញយកផលចំណេញនយោបាយពីពាក្យថា សន្តិសុខ និងពាក្យបំបែកបំបាក់ជាតិ នេះមកបំរើគោលនយោបាយបក្ខពួកនិងក្រុមរបស់លោក ហើយគាបសង្កត់ទៅអ្នកនយោបាយដ៏ទៃបានស្រេចតែចិត្តនោះទេ។

សេចក្តីថ្លែងការណ៍របស់លោកដែលមានលក្ខណៈជា បទបញ្ជា និងមានចរិក ព្រមទាំងចេតនាគំរាម ដល់អ្នកនយោបាយ សកម្មជនសិទ្ធមនុស្ស និងសកម្មជនតវ៉ាកិច្ចការព្រំដែន តែងតែកើតមានឡើង ហើយក៏តែងតែបង្កគ្រោះថ្នាក់ ក្រុមអ្នកនយោបាយ សកម្មជនសិទ្ធមនុស្ស និងសកម្មជនតាវ៉ាកិច្ចការព្រំដែនដែរ ។ សំណួរសួរថា តើទង្វើឆ្សៀតឆ្លក និងគ្មានការទទួលខុសត្រូវបែបនេះឬ ដែលលោកហៅថាជាលទ្ធិប្រជាធិបតេយ្យ?

ខ្ញុំសូមជំរាបលោកថា ការឃោសនានយោបាយ មិនមែនជាការឃោនាផលិតផល ឬវត្ថុសំរាប់ប្រើប្រាស់នៅលើទីផ្សារទេ ហើយអ្នកនយោបាយ និងគណៈបក្សនយោបាយនិមួយៗ ក៏មិនមែនជាមុខទំនិញ ឬវត្ថុដែលលោកត្រូវតែកំណត់ ឬក៏កិរិតព្រំដែនអោយផ្សព្វផ្សាយពាណិជ្ជកម្មនោះតែ ។ បើលោក និងមន្ត្រីរបស់លោក មិនបានប្រព្រឹត្តិអំពើរពុករលួយ មិនបានប្រព្រឹត្តិអំពើឧក្រិដកម្ម មិនបានប្រព្រឹត្តិអំពើលក់ជាតិ ឬ ក្បត់ជាតិ តើខ្លាចអីនឹងប្រឈមមុខជាមួយការពិត? អោយតែរឿងរ៉ាវទាំងនោះជាការពិត មិនថាតែអ្នកអ្នកនយោបាយទេ គឺប្រជាពលរដ្ឋខ្មែរទាំងអស់មានសិទ្ធនិងកាតព្វកិច្ចនិយាយចេញមកក្រៅជាសាធារណៈ ហើយការមានសេចក្តីក្លាហាន និយាយពីរឿងអំពើរពុករលួយ អំពើរឧក្រិដកម្ម អំពើរលក់ជាតិ និងអំពើរក្បត់ជាតិ របស់អ្នកនយោបាយខ្មែរ វាមិនមែនជាការបំបែកបំបាក់ជាតិសាសន៍ខ្មែរទេ ផ្ទុយទៅវិញវាជាបេសកម្មរបស់របស់ខ្មែរគ្រប់រូបដែលត្រូវតែនិយាយ ដើម្បីបំរើអោយឧត្តមប្រយោជន៏ជាតិ និងយុត្តិធមិសង្គម និងជាពិសេសកុំអោយក្រុមអ្នកនយោបាយដែលចូលចិត្តតែទទួលត្រូវ មិនព្រមទទួលខុស បន្តធ្វើការបោកប្រាស់ប្រជាពលរដ្ឋខ្មែរតទៅទៀត ។

***សតវត្សថ្មីនេះ ប្រជាពលរដ្ឋកម្ពុជា មិនអាចរស់ប្រៀបដូចជាកង្កែបក្នុងអណ្តូងទៀតទេ ហើយអ្នកនយោបាយទាំងស្តេច និងមិនមែនស្តេច ក៏មិនអាចបន្តអួតថា ខ្លួន និងបក្ខពួកគឺជា ក្រុមអ្នកមានបុណ្យ ឬជាពូជទេវតា មកចាប់ជាតិ អីទៀតដែរ ។***

ដោយការភាតរៈ និងការរាប់អាន ។

**សួន សេរីរដ្ឋា**

អគ្គលេខាធិការ CSRI